ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទបង្ហាញ
# ស្តីពី
# លទ្ធផលនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងវិស័យអប់រំ

ឯកឧត្តម ថោង បូរ៉ាន់ អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា
រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០១៨

# មាតិកា

I. សេចក្តីផ្តើម

II. ស្ថានភាពទូទៅ

□□□. វឌ្ឍនភាពធៀបទៅនឹងសូចនាករ

១. ការរៀបចំរចនាសម្ព័ន្ធនិងការពិពណ៌នាមុខតំណែង

២. ការកសាងសមត្ថភាពមន្ត្រី

៣. ការរៀបចំប្រព័ន្ធបៀវត្សមន្ត្រីរាជការ

៤. ប្រព័ន្ធគ្រប់គ្រងគុណផល

៥. ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ

៦. ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្ស

៧. ការផ្តល់សេវាសាធារណៈ

□□. បញ្ហាប្រឈម

□. ទិសដៅ

## I. សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងចូលរួមជាមួយរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្ត **កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ** ដើម្បីធ្វើឱ្យប្រសើរឡើងលើការងារ៖

១. ការផ្តល់សេវាអប់រំគ្រប់ភូមិសិក្សា

២. ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅគ្រប់អង្គភាព

៣. ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា

៤. ការគ្រប់គ្រងថវិកាតាមប្រព័ន្ធព័ត៌មានវិទ្យា

៥. និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស

# II. ស្ថានភាពទូទៅ

គិតត្រឹមដំណាច់ឆ្នាំសិក្សា២០១៦ - ២០១៧ ក្រសួងមាន៖

- គ្រឹះស្ថានសិក្សាចំណេះទូទៅ សរុបៈ ១២ ៨៨៩ សាលា ថ្នាក់រៀន សរុបៈ ៨៦ ៧១៣ ថ្នាក់

. សាលាមត្តេយ្យសិក្សា ៖ ៤ ០១៤ សាលា
. សាលាបឋមសិក្សា ៖ ៧ ១៤៤ សាលា
. អនុវិទ្យាល័យ(ថ្នាក់ទី៧ - ៩)៖ ១ ២៤៥ សាលា
. វិទ្យាល័យ(ថ្នាក់ទី១០ - ១២)៖ ៣២ សាលា
. វិទ្យាល័យ(ថ្នាក់ទី៧ - ១២) ៖ ៤៧៩ សាលា

- គ្រឹះស្ថានឧត្តមសិក្សា សរុបៈ ១២១ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សា រដ្ឋ ៤៨ និងឯកជន ៧៣
- បុគ្គលិកអប់រំក្របខណ្ឌ សរុបៈ ១១៩ ៣៦៨នាក់ ស្រី ៤៥,៥០% នៅថ្នាក់កណ្តាល ៣ ២៣៧នាក់ ស្រី ២៧,២៧% និងថ្នាក់រាជធានី ខេត្ត ១១៦ ១៣១នាក់ ស្រី ៤៦%
- មន្ត្រីជាប់កិច្ចសន្យា សរុបៈ ៥៤៣នាក់ ស្រី ៣៧,៩៧% និងគ្រូបង្រៀនជាប់កិច្ចសន្យា សរុបៈ ៨ ៨២៤នាក់ ស្រី ៤៥,២៩%

## III. ឧបសម្ពន្ធភាពធៀបទៅនឹងសូចនាករ

### ១. ការរៀបចំរចនាសម្ព័ន្ធនិងការពិពណ៌នាមុខតំណែង

- ក្នុងការរៀបចំរចនាសម្ព័ន្ធ ក្រសួងបានអនុវត្តតាមអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ក្រសួងបានរៀបចំការពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីគ្រប់គ្រងចាប់អនុប្រធានការិយាល័យថ្នាក់កណ្តាល រហូតដល់អគ្គនាយក និងថ្នាក់រាជធានី ខេត្ត ចាប់ពីអនុប្រធានការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ រហូតដល់ប្រធានមន្ទីរ
- បានធ្វើបច្ចុប្បន្នភាពលើ ការពិពណ៌នាមុខតំណែងបុគ្គលិកអប់រំ

# III. វឌ្ឍនភាពធៀបទៅនឹងសូចនាករ

## ២. ការកសាងសមត្ថភាពមន្ត្រី

- បានកសាងផែនការអភិវឌ្ឍនសមត្ថភាពមន្ត្រីរាជការរយៈពេលមធ្យម (CDPF) ដោយមានការគាំទ្រថវិកាពីដៃគូអភិវឌ្ឍ
- បានកសាងគោលនយោបាយ និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍគ្រូបង្រៀន
- បានកសាងគោលនយោបាយនិងផែនការសកម្មភាពស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ
- អនុវត្តគោលការណ៍បណ្តុះបណ្តាលគ្រូបឋម មត្តេយ្យដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្នុងពេលវិស្សមកាល២ដង ដើម្បីតាំងស៊ប់ក្នុងក្របខណ្ឌជាគ្រូកម្រិតមូលដ្ឋាន

# III. វឌ្ឍនភាពធៀបទៅនឹងសូចនាករ

## ២. ការកសាងសមត្ថភាពមន្ត្រី

- អនុញ្ញាតឱ្យគ្រូបង្រៀនដែលមានសញ្ញាបត្រ(ទុតិយភូមិ និងឧត្តម) ចុះឈ្មោះប្រឡងចូលរៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដើម្បីប្តូរក្របខណ្ឌទៅកម្រិតខ្ពស់ជាង
- អនុវត្តគោលការណ៍បណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿន ដើម្បីតាំងស៊ប់ក្នុងក្របខណ្ឌជាគ្រូកម្រិតឧត្តម និងចាត់តាំងឱ្យទៅបង្រៀននៅវិទ្យាល័យដែលកំពុងខ្វះគ្រូបង្រៀន
- អនុវត្តគោលការណ៍បណ្តុះបណ្តាលអធិការមធ្យមសិក្សាតាមវិធីថ្មី
- សហការជាមួយសាលាភូមិន្ទរដ្ឋបាល បណ្តុះបណ្តាលនាយកសាលាចំណេះទូទៅលើការងារៈ គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងធនធានមនុស្ស ថវិកា.....

# III. ចន្លោះភាពធៀបទៅនឹងស្ដង់ដា

## ៣. ការរៀបចំប្រព័ន្ធបៀវត្សមន្ត្រី

- ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់បុគ្គលិកអប់រំនៅទូទាំងប្រទេស ប្រាក់បង្រៀនម៉ោងបន្ថែម បង្រៀនពីរថ្នាក់ពីរពេល និងប្រាក់ឧបត្ថម្ភ គ្រូបង្រៀនតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាក និងគ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវបានដាក់ឱ្យបើកតាមប្រព័ន្ធធនាគារ
- បញ្ចូលទិន្នន័យមន្ត្រីជាប់កិច្ចសន្យា(ថ្នាក់កណ្ដាល)ទៅក្នុងប្រព័ន្ធទិន្នន័យរួមរបស់ក្រសួងមុខងារសាធារណៈ និងដាក់ឱ្យបើកប្រាក់ឧបត្ថម្ភតាមប្រព័ន្ធធនាគារ
- ពិនិត្យតាមដាន និងបង្កកប្រាក់បៀវត្សបុគ្គលិកអប់រំដែលបោះបង់ឬអសកម្មការងារ និងចាត់វិធានការរដ្ឋបាល
- អនុវត្តការគ្រប់គ្រងថវិកាតាមប្រព័ន្ធព័ត៌មានវិទ្យា

# III. វឌ្ឍនភាពធៀបទៅនឹងសូចនាករ

### ៤. ប្រព័ន្ធគ្រប់គ្រងគុណផល

- ផ្សព្វផ្សាយគោលការណ៍ស្ដីពីការអនុវត្តប្រព័ន្ធវាយតម្លៃគុណផល និងជំរុញការអនុវត្តសាកល្បង នៅអង្គភាពថ្នាក់កណ្ដាល

### ៥. ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ

- ក្រសួងបានបង្កើតនាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ
- ផលិតរបាយការណ៍សមិទ្ធកម្មវិស័យអប់រំ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- កសាងឯកសារស្ដីពីការធ្វើអធិការកិច្ចជាប្រព័ន្ធលើ ការគ្រប់គ្រងសាលារៀន និងការបង្រៀន
- ចាត់តាំងក្រុមការងារក្រសួងចុះពិនិត្យតាមដាននិងវាយតម្លៃជាប្រចាំ លើ ការងារគ្រប់គ្រងបុគ្គលិក ការងារគ្រប់គ្រងហិរញ្ញវត្ថុ.....នៅតាមអង្គភាពនានា

# III. វឌ្ឍនភាពធៀបទៅនឹងសូចនាករ

## ៦. ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងធនធានមនុស្ស

- បានបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS) គ្រប់គ្រងដោយនាយកដ្ឋានបុគ្គលិក សម្រាប់ក្របខណ្ឌទូទាំងប្រទេស និងដោយ ឡែកនៅតាមមន្ទីរ អយក រាជធានី ខេត្ត ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាដើម្បីគ្រប់គ្រងការដំឡើងថ្នាក់បុគ្គលិកអប់រំ

## ៧. ការផ្ដល់សេវាសាធារណៈ

- បង្កើតសាលារៀនជំនាន់ថ្មី
- បង្កើតសាលាមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេសនៅវិទ្យាល័យ
- កែទម្រង់ការប្រឡងគ្រប់ប្រភេទ
- ប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ឱ្យទៅជាវិទ្យាស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន (១២ + ៤ )
- បានបំពាក់សម្ភារអេឡិចត្រូនិច និងប្រព័ន្ធព័ត៌មានវិទ្យានៅតាមគ្រឹះស្ថានសិក្សាមួយចំនួនដើម្បីសម្រួលដល់ការស្រាវជ្រាវ
- បានពន្លឿនការបញ្ជាក់សញ្ញាបត្រកម្រិតឧត្តមសិក្សា និងការបោះពុម្ពសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

# IV. បញ្ហាប្រឈម

- ការប្រើប្រាស់ធនធានមនុស្សនៅតាមអង្គភាពរដ្ឋបាលភាគច្រើន មិនទាន់បានសមស្របតាមមុខជំនាញឯកទេស និងការពិពណ៌នាមុខតំណែង
- ការអនុប្រព័ន្ធវាយតម្លៃគុណផលមិនទាន់មានប្រសិទ្ធភាព ដោយខ្វះគោលការណ៍លើកទឹកចិត្ត
- មានការយឺតយ៉ាវលំហូរឯកសារស្ដីពីស្ថានភាពបុគ្គលិកដែលត្រូវឆ្លងក្រសួងពាក់ព័ន្ធ
- របនាសម្ព័ន្ធនៅតាមអង្គភាពមួយចំនួនមិនទាន់មានសង្គត់ភាពជាមួយនឹងគោលការណ៍ណែនាំថ្មីៗ

# V. ទិសដៅ

- បន្តធ្វើបច្ចុប្បន្នភាពរចសម្ព័ន្ធគ្រប់គ្រងនៅតាមអង្គភាពមួយចំនួន និងបន្តរៀបចំសម្រាប់អង្គភាពបង្កើតថ្មី
- ជំរុញការអនុវត្តភារកិច្ចមន្ត្រីរាជការតាមការពិពណ៌នាមុខតំណែង
- បន្តធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS)
- ដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងសម្ភារនិងទ្រព្យសម្បត្តិរដ្ឋ
- ពិនិត្យតាមដាននិងជំរុញការគ្រប់គ្រងថវិកាតាមប្រព័ន្ធព័ត៌មានវិទ្យា
- បន្តអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ


សូមអរគុណ